# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១
ខិត្តប័ណ្ណព័ត៌មាន




*ខែតុលា ឆ្នាំ២០២៣*

ទិន្នន័យបង្ហាញជូននៅក្នុងខិត្តប័ណ្ណព័ត៌មាននេះ គឺត្រូវបានដកស្រង់ចេញពីរបាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្នុងកិច្ចសហការប្រតិបត្តិការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងk ការគាំទ្របច្ចេកទេសពីអង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) នៅក្រោមវិសាលភាព នៃគំនិតផ្តួចផ្តើមរបស់អង្គការ 50x2030 ដើម្បីបិទបញ្ចប់កង្វះខាតទិន្នន័យស្ថិតិកសិកម្ម។ អង្គការ 50 x2030 គឺជាគំនិតផ្តួចផ្តើមម្ចាស់ជំនួយពហុភាគីដែលអនុវត្តតាមភាពជារយៈដៃគូ ពិសេសរវាងធនាគារពិភពលោក អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) ក្នុងគោលបំណងកសាងសមត្ថភាពស្ថិតិថ្នាក់ជាតិ និងបង្កើតប្រព័ន្ធប្រមូលទិន្នន័យកសិកម្មថ្នាក់ជាតិមួយប្រកបដោយប្រសិទ្ធភាព និងស្ថេរភាពយូរអង្វែង។

## ១. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត

នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាចំនួនពីរ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកធ្វើអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ បន្ទាប់ពីបានធ្វើអង្កេតចន្លោះជំរឿនកសិកម្ម ឆ្នាំ២០១៩ (CIAS 2019) និងអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២០ ។ ការអង្កេតថ្នាក់ជាតិនេះបានប្រមូលព័ត៌មានស្ដីពីការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី វារីវប្បកម្ម និងនេសាទ សេដ្ឋកិច្ចកសិកម្ម និងកម្លាំងពលកម្ម។

**រូបទី ១ ៖ ទិដ្ឋភាពទូទៅ នៃវិធីសាស្ត្រអង្កេត**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

វិធីសាស្ត្រជ្រើសរើសសំណាកគំរូ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ត្រូវបានធ្វើការស្រង់បញ្ជីគ្រួសារឡើងវិញ និងពិនិត្យរកមើលគ្រួសារកសិកម្ម។ វិធីសាស្ត្រស្ថិតិត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសសំណាកគំរូ ដែលតំណាងឱ្យមណ្ឌលអង្កេត តាមរយៈបញ្ជីមេជ្រើសរើសគំរូ នៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។ គ្រួសារនៅក្នុង មណ្ឌលអង្កេតទាំងនេះត្រូវបានពិនិត្យ រកមើលគ្រួសារចូលរួមធ្វើសកម្មភាពខាងផ្នែកកសិកម្ម។ ដោយប្រើប្រាស់ព័ត៌មានជំរឿនទូទៅប្រជាជនជាមូលដ្ឋាន គ្រួសារធ្វើការកសិកម្មត្រូវបានផ្ដុំតាមក្រុម ឬស្រទាប់ និងរៀបចំជ្រើសរើសសំណាកគំរូដើម្បីសម្ភាស ប្រមូលទិន្នន័យលំអិតបន្ថែម។ ការកាន់កាប់កសិកម្មនីតិបុគ្គល ឬជាសហគ្រាសកសិកម្មខ្នាតធំ ដែលគ្រប់គ្រងដោយក្រុមហ៊ុន សាជីវកម្ម ឬស្ថាប័នរដ្ឋ ក៏ត្រូវបានធ្វើអង្កេតផងដែរ ដោយផ្អែកលើបញ្ជីឈ្មោះបានផ្ដល់ឱ្យ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យរដ្ឋាភិបាលដទៃទៀតដែលបានដឹងថាជាជាសហគ្រាសកសិកម្មនីតិបុគ្គល។

អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ បានប្រើប្រាស់វិធីសាស្ត្រសម្ភាស ប្រមូលទិន្នន័យដោយមានកុំព្យូទ័ជំនួយ CAPI និងបច្ចេកវិទ្យាម៉ាស៊ីនថេប្លេត ដើម្បីកត់ត្រាការសម្ភាសន៍ និងគ្រប់គ្រងទិន្នន័យ។

**រូបទី ២ ៖ អ្នកនេសាទម្នាក់ពិនិត្យសំណាញ់ការនេសាទត្រីរបស់គាត់នៅខេត្តបន្ទាយមានជ័យ ប្រភព៖ រូបថត FAO ឆ្នាំ២០២២**



ការធ្វើសម្ភាសន៍គ្រួសារកសិកម្មចាប់ផ្ដើមពីថ្ងៃទី១៣ ដល់ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ហើយការធ្វើសម្ភាសន៍សហគ្រាសកសិកម្មខ្នាតធំចាប់ផ្ដើមពីថ្ងៃទី១៣ ដល់ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១។ ការអង្កេតប្រើប្រាស់មន្ត្រីសរុបទាំងអស់ចំនួន ៤២៩ នាក់ (ក្នុងនោះមន្ត្រីសម្ភាសន៍ចំនួន ៣៣៧នាក់ មន្ត្រីត្រួតពិនិត្យការសម្ភាសន៍ចំនួន ៤៦ នាក់ និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤៦ នាក់) គ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១៦.៥៧២ គ្រួសារ ត្រូវបានសម្ភាសបញ្ចប់សពេញលេញ និងសហគ្រាសកសិកម្មខ្នាតធំចំនួន ៤៧០ សហគ្រាស ត្រូវបានសម្ភាសន៍ផងដែរ នៅទូទាំង២៥ រាជធានីខេត្ត នៃប្រទេសកម្ពុជា។ ខិត្តប័ណ្ណផ្សព្វផ្សាយព័ត៌មានស្ថិតិ បង្ហាញពីរបកគំឃើញចម្បង នៃការអង្កេតកសិកម្មកម្ពុជា ឆ្នាំ ២០២១ ដោយផ្ដោតលើការកាន់កាប់កសិកម្មលក្ខណៈគ្រួសារប៉ុណ្ណោះ។

## ២. គ្រួសារកាន់កាប់កសិកម្ម

អង្កេតកសិកម្មកម្ពុជា ឆ្នាំ ២០២១ ត្រូវបានប៉ាន់ស្មានថា គ្រួសារកាន់កាប់កសិកម្មនៅកម្ពុជាមានសរុបចំនួន ២.២២៦.០០០ គ្រួសារ។ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានប៉ាន់ប្រមាណថា ចំនួនគ្រួសារកាន់កាប់កសិកម្មសរុបមានចំនួន

៣.៥៥៣.០២១ គ្រួសារ នៅទូទាំងប្រទេសកម្ពុជា។ ដូច្នេះប្រហែលជា ៦៣ ភាគរយ នៃគ្រួសារទាំងអស់ត្រូវបានចូលរួមក្នុងផលិតកម្មកសិកម្ម។

គ្រួសារកាន់កាប់កសិកម្មទាំងនោះត្រូវបានចែកទៅតាមតំបន់ភូមិសាស្ត្រសង្គម នៃប្រទេសកម្ពុជា ៖ តំបន់វាលទំនាប មានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេបំផុត ៤៣ភាគរយ បន្ទាប់មកគឺ តំបន់បឹងទន្លេសាបមាន ៣៥ ភាគរយ  តំបន់ភ្នំ និងខ្ពង់រាបមាន ១៥ភាគរយ និងចុងក្រោយតំបន់ឆ្នេរសមុទ្រមាន ៧ភាគរយ ។

**រូបទី ៣ ៖ គ្រួសារកសិកម្មបែងចែកតាមតាមតំបន់ភូមិសាស្ត្រ**




**រូបទី ៤ ៖ ចំនួនគ្រួសារ និងភាគរយនៃគ្រួសារកសិកម្មចែកតាមតំបន់ គិតជាពាន់**




ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១

គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា ៥៨ភាគរយ ត្រូវបានរាយការណ៍ថា៖ គោលបំណងចម្បងនៃការធ្វើកសិកម្មរបស់ពួកគាត់ គឺដើម្បីសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ ខណៈដែល ៤២ភាគរយ នៃគ្រួសារកសិកម្មបានឆ្លើយថា គោលបំណងចម្បងនៃការធ្វើកសិកម្ម គឺសម្រាប់លក់។ បំណែងចែកតាមតំបន់មាន ៨៥ភាគរយ នៃគ្រួសារកសិកម្មនៅតំបន់ឆ្នេរសមុទ្រ បានធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ បន្ទាប់មកមាន ៥៩ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់ ភ្នំ និងខ្ពង់រាប ហើយមាន ៥៨ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់ វាលទំនាប និងនៅតំបន់ បឹងទន្លេសាប ៥២ភាគរយ នៃគ្រួសារកសិកម្ម បានធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ។

**រូបទី ៥ ៖ ភាគរយ នៃគ្រួសារកសិកម្មរាយការណ៍ពីគោលបំណងចម្បងនៃការធ្វើកសិកម្មរបស់ពួកគាត់**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

## ៣. សកម្មភាពផលិតកម្មដំណាំ

ការអង្កេតនេះបានប៉ាន់ប្រមាណថា មានគ្រួសារកាន់កាប់កសិកម្មប្រមាណ ២.០៤៨.៥៤០ គ្រួសារ នៃគ្រួសារកាន់កាប់កសិកម្មសរុប ២.២២៦.០០០ គ្រួសារ ស្មើនឹង ៩២ភាគរយ បានធ្វើសកម្មភាពដាំដំណាំ ។ ប្រភេទដំណាំជាច្រើនមុខត្រូវបានគេរាយការណ៍ក្នុងអំឡុងពេលប្រមូលទិន្នន័យ ប៉ុន្តែការអង្កេតគឺផ្តោតលើដំណាំចម្បងចំនួន ៣០មុខដំណាំតែប៉ុណ្ណោះដែលបានជ្រើសរើស ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលព័ត៌មានលម្អិតស្តីពីផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផល ការប្រើប្រាស់ (ជី ថ្នាំសម្លាប់សត្វល្អិត ប្រព័ន្ធស្រោចស្រព)និងបរិមាណផលទទួលបាន។

ការអង្កេតនេះបានចាត់ចំណាត់ថ្នាក់ដំណាំចម្បង ចំនួនបួនមុខដំណាំ ដែលគ្រួសារកសិកម្មបានដាំដុះច្រើនជាងគេ នៅក្នុងតំបន់ធំទាំងបួននៃប្រទេសកម្ពុជា។ ស្រូវធម្មតាត្រូវបានរកឃើញថាជា ប្រភេទដំណាំ ដែលបានដាំច្រើនជាងគេបំផុតនៅទូទាំងប្រទេស។ ផ្អែកតាមអង្កេតកសិកម្មឆ្នាំ២០២១បានប៉ាន់ប្រមាណថាដំណាំស្រូវ ធម្មតាបានប្រើប្រាស់ផ្ទៃដីដាំដុះសរុបចំនួន ២,១០ លាន ហិកតា និងផ្ទៃដីបានប្រមូលផលសរុបចំនួន ២,០៨ លាន ហិកតា។ ទិន្នផលជាមធ្យមត្រូវបានប៉ាន់ប្រមាណថាមានចំនួន ២.៧ តោន ក្នុងមួយហិកតា ខណៈដែលបរិមាណផលស្រូវធម្មតាសរុបទូទាំងប្រទេស ត្រូវបានប៉ាន់ប្រមាណចំនួន ៥,៨៩ លាន តោន។

ការអង្កេតបានបង្ហាញថា នៅប្រទេសកម្ពុជាបានដាំដុះដំណាំហូបផ្លែច្រើនប្រភេទ រួមមាន៖ ស្វាយ ចេក ទៀប ស្រកានាគ ទុរេន ត្របែក ខ្នុរ ព្រីង មៀន ទឹកដោះគោ ល្ហុង និងម្នាស់។ ដំណាំស្វាយជាដំណាំដែលកសិករពេញនិយមដាំជាងគេជាប់លំដាប់ទីពីរ នៅតំបន់បឹងទន្លេសាប និងតំបន់ភ្នំ និងខ្ពង់រាប (ក្នុងលក្ខខណ្ឌគ្រួសារកាន់កាប់កសិកម្មដែលបានរាយការណ៍ថាគាត់បានដាំដុះដំណាំស្វាយ)។ ចំណែកឯនៅតំបន់វាលទំនាប ដំណាំចេកជាប់លំដាប់ទីពីរ ខណៈដែលដំណាំស្វាយជាប់លំដាប់ទីបី និងនៅតំបន់ ឆ្នេរសមុទ្រ ដំណាំដូងជាប់លំដាប់ទីពីរ ដំណាំចេកជាប់លំដាប់ទីបី និងដំណាំស្វាយនៅលំដាប់ទីបួន។ នៅទូទាំងប្រទេសផ្ទៃដីដាំដុះដំណាំស្វាយមានប្រមាណ ១១៣.៦៧០ ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ៨២.៤៤០ ហិកតា។

រូបទី ៦ ៖ ដំណាំចម្បងបួនប្រភេទដែលបានដាំច្រើនជាងគេនៅក្នុងតំបន់នីមួយៗ (ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍)

**តំបន់វាលទំនាប៖**
871,280 គ្រួសារ
1. ស្រូវធម្មតា
2. ចេក
3. ស្វាយ
4. ដូង

**តំបន់បឹងទន្លេសាប៖**
731,630 គ្រួសារ
1. ស្រូវធម្មតា
2. ស្វាយ
3. ចេក
4. ដូង

**2,048,540 គ្រួសារកាន់កាប់កសិកម្មបានធ្វើសកម្មភាពដាំដំណាំនៅទូទាំងប្រទេសកម្ពុជា**

**តំបន់ឆ្នេរសមុទ្រ៖**
138,950 គ្រួសារ
1. ស្រូវធម្មតា
2. ដូង
3. ចេក
4. ស្វាយ

**តំបន់ភ្នំ និងខ្ពង់រាប៖**
306,680 គ្រួសារ
1. ស្រូវធម្មតា
2. ស្វាយ
3. ស្វាយចន្ទី
4. ចេក

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

ដំណាំចេកជាដំណាំស្ថិតក្នុងប្រភេទដំណាំដែល ពេញនិយមបំផុត ទាំងបួនតំបន់ ហើយនៅតំបន់វាលទំនាបដំណាំចេកស្ថិតនៅ ចំណាត់ថ្នាក់ទី២ ។ ដោយឡែកនៅតំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ ដំណាំចេកជាប់ចំណាត់ថ្នាក់លេខបី និងនៅតំបន់ ភ្នំ និងខ្ពង់រាប វិញដំណាំចេកជាប់ចំណាត់ថ្នាក់លេខបួន។ តាមការប៉ាន់ប្រមាណឃើញថាដំណាំចេកបានដាំលើផ្ទៃដីប្រមាណ ៩.៨០០ ហិកតា ហើយបានប្រមូលផលលើផ្ទៃដី ៦.៦៩០ ហិកតា ដោយទទួលបរិមាណផលប្រហែល ៣៦.៣២៩ តោន។

## ៤. សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី

ការចិញ្ចឹមបសុសត្វ បសុបក្សីជាសកម្មភាពកសិកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ការចិញ្ចឹមសត្វជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និងផ្តល់ចំណូលដល់គ្រួសារកាន់កាប់កសិកម្មប្រមាណ ១.៦១០.០០០ គ្រួសារ ស្មើនឹង ៧២ ភាគរយ នៅទូទាំងប្រទេស។ នៅតំបន់ឆ្នេរសមុទ្រ គ្រួសារកាន់កាប់កសិកម្ម បានរក្សាទុក ឬចិញ្ចឹមបសុសត្វ និង/ឬបសុបក្សីច្រើនជាងបំផុតប្រមាណជា ៨៤ ភាគរយ និងមានភាគរយទាបជាងគេបំផុត គឺនៅតំបន់វាលទំនាបមានប្រមាណ ៦៩ ភាគរយ។ តាមការប៉ាន់ប្រមាណនៅទូទាំងប្រទេស មានគ្រួសារចិញ្ចឹមសុបក្សីចំនួន ១.២៦០.០០០ គ្រួសារ និងគ្រួសារចិញ្ចឹមសត្វគោមានចំនួន ៧៨០.០០០ គ្រួសារ។

រូបទី ៧ ៖ ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ថាមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី បែងចែកតាមតំបន់ភូមិសាស្ត្រ សង្គម (គិតជាពាន់)




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

នៅតំបន់វាលទំនាប គឺជាតំបន់ដែលមានគ្រួសារកាន់កាប់កសិកម្មចិញ្ចឹមសត្វគោចំនួន ច្រើនជាងគេ បំផុត (៣៥៧.០០០ គ្រួសារ កាន់កាប់កសិកម្ម) បន្ទាប់មកនៅតំបន់បឹងទន្លេសាប មានចំនួន ២៥៤.០០០ គ្រួសារ ហើយនៅតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១០៧.០០០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រ មានចំនួន ៦០.០០០ គ្រួសារ ។



នៅតំបន់វាលទំនាបបានបង្ហាញថាមានចំនួនគ្រួសារចិញ្ចឹមបសុបក្សីច្រើនជាងគេ គឺចំនួន ៤៨២.០០០ គ្រួសារ បន្ទាប់មក គឺនៅតំបន់បឹងទន្លេសាប មានគ្រួសារចំនួន ៤៤៩.០០០ គ្រួសារ ហើយនៅតំបន់ ភ្នំ និងខ្ពង់រាប មានគ្រួសារចំនួន ២០៥.០០០ គ្រួសារ និងនៅតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារចិញ្ចឹមបសុបក្សីតិចជាងគេ គឺមានចំនួន ១២៣.០០០ គ្រួសារ។

តួលេខថ្នាក់ជាតិបានបង្ហាញថា ចំនួនសត្វគោជាមធ្យមក្នុង១គ្រួសារចិញ្ចឹមគោមានចំនួន ៤,៦ ក្បាល។ ចំណែកគ្រួសារចិញ្ចឹម បសុបក្សីជាមធ្យមមានចំនួន ៧១,៧ ក្បាលក្នុង១គ្រួសារកាន់កាប់កសិកម្ម។

## ៥. ការធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទ

ការធ្វើវារីវប្បកម្ម គឺជាសកម្មភាពសេដ្ឋកិច្ចបន្ថែមដែលធ្វើឡើងដោយគ្រួសារកាន់កាប់កសិកម្ម ៤ ភាគរយ តាមការប៉ាន់ប្រមាណមានចំនួន ៨៩.០៥០ គ្រួសារ នៃគ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពវារីវប្បកម្មដែលប៉ាន់ប្រមាណ ២១ ភាគរយ នៃគ្រួសារកសិកម្ម ស្មើនឹងចំនួន ៤៧៦.៦៣០ គ្រួសារ។ គ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពទាំងពីរ ធ្វើវារីវប្បកម្ម និងនេសាទ គឺមានចំនួន ២៦.៧៩០ គ្រួសារ ស្មើនឹង ១,២ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មសរុប។

តំបន់ដែលមានចំនួនគ្រួសារច្រើនបំផុតធ្វើវារីវប្បកម្ម គឺនៅតំបន់វាលទំនាបមានចំនួន ៦០.៤៥០ គ្រួសារ ស្មើនឹង ៦ ភាគរយ នៃគ្រួសារកសិកម្មសរុប។ ចំណែកឯនៅតំបន់បឹងទន្លេសាបវិញគឺមានគ្រួសារកសិកម្មធ្វើសកម្មភាពនេសាទច្រើនជាងគេបំផុត គឺចំនួន ២២៣.០៨០ គ្រួសារស្មើនឹង ២៨ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មសរុប។

**រូបទី ៩ ៖ ចំនួនគ្រួសារកសិកម្មបានរាយការណ៍ថាមានសកម្មភាព វារីវប្បកម្ម និង ឬនេសាទ ចែកតាមតំបន់ភូមិសាស្ត្រ**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

ក្នុងចំណោមគ្រួសារកសិកម្មបានធ្វើសកម្មភាពនេសាទទាំងនោះ គឺមាន ៧៩.១ភាគរយ បានរាយការណ៍ថានេសាទត្រី ហើយ ១២ភាគរយ បានរាយការណ៍ថានេសាទ/ចាប់ក្តាម និង ៥ភាគរយ រាយការណ៍ពីការនេសាទ/រកខ្ចង។ សម្រាប់បរិមាណផលសរុបដែលប្រមូលបានពីការនេសាទត្រីបានប្រមាណ ៣៣១លាន គីឡូក្រាម។ ប្រភេទត្រីចិញ្ចឹមភាគច្រើនក្នុងការធ្វើវារីវប្បកម្មនៅកម្ពុជា គឺ មានដូចជា ត្រីប្រាចំនួន ៦៨ លានក្បាល និង ត្រីអណ្តែងមាន ៥១លានក្បាល។

## ៦. សេដ្ឋកិច្ច និងកម្លាំងពលកម្ម

វិស័យកសិកម្មកម្ពុជា នៅតែមានសារៈសំខាន់ ដើម្បីធានាដល់ជីវភាពរស់នៅរបស់ប្រជាជន។ របាយការណ៍បានប៉ាន់ប្រមាណថាមាន ៣៥ភាគរយ បានរាយការណ៍ថាប្រហែលពាក់កណ្តាល (៤០ភាគរយ ទៅ ៥៩ភាគរយ) នៃចំណូលសរុបគ្រួសាររបស់ពួកគេបានមកពីសកម្មភាពកសិកម្ម ហើយមាន ១៦ភាគរយ បានរាយការណ៍ថាភាគច្រើន ឬស្ទើរតែទាំងអស់ (៦០ភាគរយ ទៅ ៩៩ភាគរយ) នៃចំណូលសរុបគ្រួសាររបស់ពួកគេបានមកពីសកម្មភាពកសិកម្ម និងមាន ៤ភាគរយ បានរាយការណ៍ថាទាំងអស់ (១០០ភាគរយ) នៃចំណូលសរុបគ្រួសាររបស់ពួកគេបានមកពីសកម្មភាពកសិកម្ម ។

**រូបទី ៨ ៖ ភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍មានចំណូលពីកសិកម្ម ខ្ពស់ជាង ប្រហាក់ប្រហែលគ្នា តិចជាង ប្រៀបធៀបទៅឆ្នាំមុន ចែកតាមតំបន់**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

គ្រួសារប្រហែល មួយភាគបី ប្រមាណ ២៧ភាគរយ បានរាយការណ៍ថា៖ ប្រាក់ចំណូលពីកសិកម្មបានចូលរួមចំណែកនៃចំណូលសរុបក្នុងគ្រួសារបានធ្លាក់ចុះទាបជាងឆ្នាំមុន ហើយមាន ៦៧ ភាគរយមានចំណូលប្រហាក់ប្រហែលទៅឆ្នាំមុន និងមានប្រមាណ ៦ ភាគរយមានចំណូលច្រើនជាងឆ្នាំមុន។

គ្រួសារកសិកម្មចំនួន ៩៨ភាគរយ មានដីកម្មសិទ្ធិផ្ទាល់ខ្លួនសម្រាប់ធ្វើកសិកម្ម។ ភាគច្រើននៃដីនោះបានមកពីការទិញ ហើយតម្លៃដីនៅទូទាំងប្រទេស មានការកើនឡើងជាលំដាប់គឺ ចាប់ពីតម្លៃ ២.៦០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយហិចតា នៅក្នុងឆ្នាំ ២០០០ កើនរហូតដល់ ៧.៥០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយហិចតា នៅឆ្នាំ ២០២១ ។

សម្រាប់និន្នាការ ការងារកសិកម្មនៅកម្ពុជាបានបង្ហាញថាបានប្រើប្រាស់កម្មករធ្វើការម្តងម្កាលច្រើនគួរឲ្យកត់សម្គាល់។ ចាប់ពីខែ កក្កដា ឆ្នាំ២០២០ ដល់ ខែមិថុនា ឆ្នាំ២០២១ គ្រួសារកសិកម្មចំនួន ៤៦៤.០០០ គ្រួសារ បានប្រើប្រាស់ពលកម្មកម្មករធ្វើការម្តងម្កាលមកធ្វើការងារកសិកម្មរបស់ពួកគេ។ ក្នុងនោះនៅតំបន់បឹងទន្លេសាបមានគ្រួសារកសិកម្មចំនួន ២០៤.០០០ គ្រួសារ បាន ប្រើប្រាស់ពលកម្មកម្មករធ្វើការម្តងម្កាលច្រើនជាងគេ ខណៈដែលនៅតំបន់ ឆ្នេរសមុទ្រ មានគ្រួសារកសិកម្មប្រើប្រាស់ពលកម្មកម្មករធ្វើការម្តងម្កាលតិចជាងគេគឺមានចំនួន ១៩.០០០ គ្រួសារ។

នៅទូទាំងប្រទេសកម្ពុជា ចំនួនកម្មករធ្វើការម្តងម្កាល មានប្រមាណ ២.៦៣៣.១០០ នាក់ ក្នុងនោះមានស្ត្រី ៤៩,២ភាគរយ និង បុរស ៥០,៨ ភាគរយ ដែលបានចូលរួមការងារក្នុងគ្រួសារកសិកម្ម។ នៅតំបន់ ភ្នំ និង ខ្ពង់រាប មានកម្មករធ្វើការម្តងម្កាលជាស្ត្រីច្រើនជាងគេ ស្មើនឹង ៦២,៨ភាគរយ ចំណែកឯនៅតំបន់ ឆ្នេរសមុទ្រវិញ មានកម្មករធ្វើការម្តងម្កាលជាបុរសច្រើនជាងគេស្មើនឹង ៦៩,៥ភាគរយ។ តួលេខនេះបង្ហាញថាភាពខុសប្លែកគ្នារវាងយេនឌ័រនៅតែមាន។

## ៧. បញ្ហា Covid-19 និងគ្រោះមហន្តរាយ

តាមការប៉ាន់ប្រមាណថាមានគ្រួសារកសិកម្មប្រមាណ ៣៥ភាគរយបានរងគ្រោះមហន្តរាយធ្ងន់ធ្ងរក្នុងអំឡុងរយៈពេល ១២ខែកន្លងមកដោយសារខ្យល់ព្យុះ ទឹកជំនន់ បាក់ដី គ្រោះរាំងស្ងួត និងមហន្តរាយផ្សេងៗទៀតរាប់បញ្ចូលទាំង មហន្តរាយដោយសត្វចង្រៃបំផ្លាញដំណាំ ជំងឺដំណាំ ជំងឺសត្វ។ តាមការប៉ាន់ប្រមាណកម្រិតថ្នាក់ជាតិមានគ្រួសារកសិកម្មប្រមាណ ២៩៧.០០០គ្រួសារ (១៣ភាគរយ) បានរងផលប៉ះពាល់ដោយគ្រោះមហន្តរាយទាំងនោះ ក្នុងចំណោមនោះដែរក៏មានគ្រួសារមួយចំនួនរងផលប៉ះពាល់ដោយសារបញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩ ផងដែរ។ គ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេក្នុងឆ្នាំ ២០២១ គឺគ្រោះរាំងស្ងួត (ប៉ះពាល់ដល់គ្រួសារកសិកម្មចំនួន ២៤៤.០០០ គ្រួសារ) បន្ទាប់មកគឺ គ្រោះទឹកជំនន់ (ប៉ះពាល់ដល់គ្រួសារកសិកម្មចំនួន ២០៦.០០០ គ្រួសារ) និងបញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩ (ប៉ះពាល់ដល់គ្រួសារកសិកម្មចំនួន ១៣១.០០០ គ្រួសារ) ។

**រូបទី ១១ ៖ សកម្មភាពចុះប្រមូលទិន្នន័យគ្រួសារកសិកម្មដោយរក្សាគម្លាតសង្គម និង**



**ពាក់ម៉ាស** (រូបថត FAO)

## ៨. ប្រភព

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ និងចេញផ្សាយរបាយការណ៍ចុងក្រោយនៅក្នុងខែតុលា ឆ្នាំ២០២៣ ។ របាយការណ៍ពេញលេញ និងកំណែឌីជីថលនៃរបាយការណ៍សង្ខេបនេះអាចរកបានតាមរយៈ Digital ស្កេន QR Code ខាងក្រោម ។

## ៩. ទំនាក់ទំនង

| អង្កេតកសិកម្មកម្ពុជា | |
|---|---|
| អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) https://www.fao.org/cambodia/en/ | តំណាងអង្គការ FAO នៅកម្ពុជា មានអាស័យដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MoP) https://www.nis.gov.kh/ | វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ(MoP) រាជរដ្ឋាភិបាលកម្ពុជា<br>អគារ C, E និង F #386 ព្រះមុនីវង្ស Blvd<br>សង្កាត់បឹងកេងកង១<br>ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) https://web.maff.gov.kh/ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)<br>255, 200 វិថីព្រះនរត្តម រាជធានីភ្នំពេញ Blvd (41) |

with a technical support of

Food and Agriculture Organization of the United Nations

with financial support of

50x2030 DATA-SMART AGRICULTURE